**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១១៧៣ ....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការនាំចេញទំនិញបណ្តោះអាសន្ន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

រដ្ឋបាលគយអាចអនុញ្ញាតឲ្យធ្វើការនាំចេញបណ្តោះអាសន្ននូវទំនិញពីដែនគយ ស្របតាមបញ្ញត្តិមាត្រា ១៧ នៃច្បាប់ស្តីពីគយ ដើម្បីគោលបំណងដូចខាងក្រោម ៖

ក- ធ្វើការជួសជុល បំប្លែង ទទួលពលកម្មបន្ថែម ឬ [illegible]

ខ- សម្រាប់តាំងពិពណ៌ ឬផ្សព្វផ្សាយពាណិជ្ជកម្ម ។

គ- ធ្វើប្រតិបត្តិការ ឬប្រើប្រាស់នៅក្រៅដែនគយ ហើយបន្ទាប់មកនាំចូលមកវិញ ដោយរាប់ទាំងទំនិញប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ។

ឃ- សម្រាប់គោលបំណងផ្សេងទៀត តាមការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ២.-**

អ្នកនាំចេញ ឬអ្នកតំណាងដែលបានទទួលសិទ្ធិ ត្រូវដាក់ជូនរដ្ឋបាលគយនូវប្រតិវេទន៍គយនាំចេញ ដោយបញ្ជាក់ថាទំនិញនោះត្រូវនាំចេញបណ្តោះអាសន្ន ។

**ប្រការ ៣.-**

ទំនិញនាំចេញបណ្តោះអាសន្នមិនត្រូវជាប់ពន្ធ និងអាករឡើយ ។

នៅពេលនាំចូលមកវិញ ពន្ធ និងអាករត្រូវបង់តែលើមូលដ្ឋានតម្លៃបន្ទុកចំណាយឯបរទេសនៃការជួសជុល បំប្លែង ឬពលកម្មបន្ថែមលើទំនិញដែលបាននាំចេញបណ្តោះអាសន្ននោះ និងបន្ទុកកម្រៃផ្សេងទៀតដែលត្រូវជាប់ពន្ធ និងអាករ ។

**ប្រការ ៤.-**

ទំនិញនាំចេញបណ្តោះអាសន្នដែលស្ថិតនៅក្នុងរយៈពេលនៃការធានា ហើយដែលពុំមានការទូទាត់តម្លៃនៃការជួសជុល ត្រូវទទួលបានការលើកលែងពន្ធ និងអាករនៅពេលនាំចូលមកវិញ ។ ប្រតិវេទករត្រូវបង្ហាញនូវសម្អាងគ្រប់គ្រាន់ដល់មន្ត្រីគយមានសមត្ថកិច្ចថា ការជួសជុលនោះធ្វើឡើងនៅក្នុងកំឡុងពេលនៃការធានា ។

**ប្រការ ៥.-**

មុនពេលអនុញ្ញាតឲ្យនាំចេញបណ្តោះអាសន្ន មន្ត្រីគយមានសមត្ថកិច្ចអាចតម្រូវឲ្យផ្តល់នូវសម្អាងដែលបង្ហាញថាទំនិញនោះត្រូវបានផលិតនៅកម្ពុជា ឬប្រសិនបើជាទំនិញនាំចូលត្រូវបង្ហាញថាទំនិញនោះបាននាំចូលដោយស្របច្បាប់ ហើយបានបង់ពន្ធ និងអាករដែលជាប់ ។

**ប្រការ ៦.-**

ទំនិញអាចត្រូវបាននាំចេញបណ្តោះអាសន្នពីដែនគយស្របតាមបញ្ញត្តិប្រការ ១ នៃប្រកាសនេះ សម្រាប់រយៈពេលអតិបរមា ១ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើប្រតិវេទន៍គយនាំចេញ ។ រដ្ឋបាលគយអាចអនុញ្ញាតពន្យាររយៈពេលនេះ [illegible] ក្នុងករណីស្នើសុំជាលាយល័ក្ខអក្សរពីប្រតិវេទករ ។

**ប្រការ ៧.-**

រដ្ឋបាលគយអាចតម្រូវឲ្យមានការតម្កល់និមុត្តិធានា ក្នុងករណីដែលទំនិញនាំចេញបណ្តោះអាសន្ននោះជាកម្មវត្ថុនៃការជាប់អាករនាំចេញ ។ ក្នុងករណីដែលទំនិញនាំចេញបណ្តោះអាសន្ននោះជាទំនិញជាប់អាយ័ត ឬទំនិញជាប់កម្រិតកំណត់ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឲ្យនាំចេញបណ្តោះអាសន្ន ទើបរដ្ឋបាលគយអាចតម្រូវឲ្យមានការតម្កល់និមុត្តិធានា ។

**ប្រការ ៨.-**

នៅពេលនាំចូលមកវិញ ប្រតិវេទករត្រូវផ្តល់សម្អាងគ្រប់គ្រាន់ដល់មន្ត្រីគយមានសមត្ថកិច្ចថា ទំនិញនោះបានធ្វើការនាំចេញបណ្តោះអាសន្ន រួមមានប្រតិវេទន៍គយនាំចេញ និងឯកសារផ្សេងទៀតដែលបង្ហាញពីតម្លៃបន្ថែមទៅលើទំនិញនោះនៅក្រៅប្រទេស ប្រសិនបើមាន ។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ ✓

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១០
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ